

# Small work Big Story

## Group art Exhibition

TOUCH SOPHONARA, MEAS SREYROTH, ROTH LINDA, NAM CHHAVIN

FROM 14TH NOVEMBER 2025 TILL 13TH JANUARY 2026

AT CAVE CAFÉ STREET 240 SECOND FLOORS

ពិព័ណ៌សិល្បៈជាក្រុមប្រធានបទ៖

# «ស្នាដៃតូច រឿងរ៉ាវធំ»

ចូលរួមដោយវិចិត្រករថ្មីចំនួនបួននាក់៖ **ទូច សុពណ្ណារ៉ា ឈាម ឆវិន រ័ត្ន លីនដា និង មាស ស្រីរ័ត្ន**

ពិព័ណ៌សិល្បៈនេះស្វែងយល់ពីការតស៊ូដ៏យូរអង្វែង និងភាពធន់ទ្រាំក្នុងជម្លោះព្រំដែនកម្ពុជា-ថៃ វាគឺជារឿងរ៉ាវអំពីដីធ្លី អត្តសញ្ញាណ និងអធិបតេយ្យភាព ដែលត្រូវបានពណ៌នាតាមរយៈស្នាដៃសិល្បៈខ្នាតតូចដែលមានឥទ្ធិពិតដ៏ខ្លាំងក្លា។ ទោះបីស្នាដៃនីមួយៗមានទំហំតូចក៏ដោយ ក៏វាសម្ដែងឱ្យឃើញនូវរបួសដ៏ជ្រៅ សេចក្ដីក្លាហាននិងភាពឯកភាពគ្នារបស់ប្រជាជនក្នុងការការពារទឹកដីរបស់ខ្លួន។ «ស្នាដៃតូច រឿងរ៉ាវធំ» ប្រែការតានតឹង និងភាពអយុត្តិធ៌ម—ដូចជាការរំលោភលើកិច្ចព្រមព្រៀងឈប់បាញ់ និងការឈ្លានពានរបស់ទាហានថៃដែលនាំយកលួសន្លាមកដាក់លើដីខ្មែរ—ឱ្យក្លាយជាសកម្មភាពនៃការអត់ធ្មត់តាមរយៈរូបភាព និងការចងចាំ។ កម្មវិធីតាំងបង្ហាញសិល្បៈនេះផ្សាយក៏ដូចជា អញ្ជើញទស្សនិកជនឱ្យឆ្លុះបញ្ចាំងអំពី អាកប្បកិរិយាអត់ធ្មត់នៃប្រជាជាតិទឹកដីតូចៗ អាចផ្ទុកនូវវិញ្ញាណនៃការស្នេហាជាតិ និងតស៊ូដើម្បីរស់នៅប្រកបដោយភាពថ្លៃថ្នូរ។

**គោលបំណង៖**

១. ដើម្បីបង្កើនការយល់ដឹងអំពីជម្លោះព្រំដែនកម្ពុជា-ថៃ និងផលប៉ះពាល់លើមនុស្ស វប្បធម៌ និងអារម្មណ៍ដែលកើតឡើងពីការរំលោភបំពានទឹកដី។

២. ដើម្បីគោរពវិរៈឌ្ឍនភាពរបស់ខ្មែរ — ដោយបង្ហាញពីភាពរឹងមាំ និងឯកភាពរបស់សហគមន៍ក្នុងការការពារដីធ្លី មរតក និងអត្តសញ្ញាណជាតិរបស់ពួកគេ។

៣. ដើម្បីប្រែការប៉ះទង្គិចគ្នាឱ្យក្លាយជាការសន្ទនា ដោយប្រើសិល្បៈជាវេទិកាសន្តិភាពដើម្បីប្រឈមមុខនឹងការឈ្លានពាន ជាមួយនិងអត់ធ្មត់ ខណៈពេលជាមួយគ្នាជំរុញការយល់ដឹងក្នុងតំបន់។

៤. ដើម្បីបង្ហាញថា ទំហំមិនកំណត់អំណាច — ស្នាដៃសិល្បៈខ្នាតតូចអាចដកស្រង់យកទំងន់នយោបាយ និងអារម្មណ៍ដ៏ធំធេង ដែលឆ្លុះបញ្ចាំងពីគំនិតដែលថា ប្រទេសតូចៗក៏អាចឈរឈ្មោះដោយមាំមួនដើម្បីយុត្តិធម៌

ដែរ។

៥. ដើម្បីជំរុញឱ្យមានការឆ្លុះបញ្ចាំង និងការយល់ឃើញពីអារម្មណ៍របស់អ្នកទស្សនា ដែលជាការបំផុសគំនិតឱ្យមានការកោតសរសើរចំពោះប្រវត្តិសាស្ត្រ អធិបតេយ្យភាព និងមោទនភាពវប្បធម៌របស់កម្ពុជាឱ្យកាន់តែស៊ីជម្រៅ។

៦. ដើម្បីកត់ត្រាការចងចាំ និងការតស៊ូតាមរយៈការបង្ហាញស្នាដៃដ៏ច្នៃប្រឌិត ដើម្បីធានាថា ពេលវេលានៃការរំលោភ និងការតស៊ូមិនត្រូវបានភ្លេចឬបំភ្លេចចោល តែត្រូវប្រែក្លាយជារឿងរ៉ាវនៃភាពរឹងមាំនៃប្រជាជាតិ។

Group art exhibition title :

# “Small Work Big Story”

## Theme

This exhibition explores the enduring struggle and resilience surrounding the Cambodia–Thailand border conflict — a story of land, identity, and sovereignty told through small-scale artworks that hold powerful truths. Though each piece may be physically small, together they reveal the deep wounds, courage, and unity of a people defending their homeland. “Small Work, Big Story” transforms moments of tension and injustice — such as the violation of the ceasefire and the intrusion of Thai troops with barbed wire into Cambodian soil — into acts of visual resistance and remembrance. The exhibition invites viewers to reflect on how even the smallest acts, gestures, or territories can embody the spirit of a nation and the struggle for dignity.

## Aims :

1. To raise awareness of the Cambodia–Thailand border conflict and the human, cultural, and emotional impact of territorial violations.
2. To honor Cambodian resilience — portraying the strength and unity of communities protecting their land, heritage, and national identity.
3. To transform conflict into dialogue, using art as a peaceful platform to confront aggression and injustice while fostering regional understanding.
4. To demonstrate that scale does not define power — small artworks can carry immense political and emotional weight, mirroring the idea that small nations can stand firmly for justice.
5. To encourage reflection and empathy among audiences, inspiring a deeper appreciation of Cambodia’s history, sovereignty, and cultural pride.
6. To document memory and resistance through creative expression, ensuring that moments of violation and struggle are not forgotten but transformed into stories of strength.

# អំពីសិល្បករ



ជីវប្រវត្តិ **ណាម ឆវិន** Nam Chhavin

កើតឆ្នាំ 1987 នៅទីរួមខេត្តបាត់ដំបង។ គាត់បានធំធាត់និងរៀនសូត្រនៅខេត្តសៀមរាប ។ ការគូររូបគឺចំណូលចិត្តតាំងពីមិនទាន់បានចូលសាលារៀន ដោយសារតែលោកឪពុករបស់គាត់ចូលចិត្តគូរ ជាហេតុធ្វើឲ្យគាត់ចង់គូរតាមលោកឪពុកគាត់ជាខ្លាំង ។ នៅថ្នាក់បឋមសិក្សា**ឆវិន** ចូលចិត្តម៉ោងគំនូរ ជីវវិទ្យា និងហត្ថកម្ម ព្រោះធ្វើអោយគាត់បានគូររូបពេញលេញ ។ ពេលរៀនចប់**ឆវិន** មិនបានរៀនមុខវិជ្ជាដែលគាត់ស្រលាញ់ពិតទេ ដោយសារកត្តាជីវភាពធ្វើអោយខកខានមិនបានមកសិក្សានៅភ្នំពេញ។ ក្នុងឆ្នាំ2022 **ឆវិន** បានផ្លាស់ប្តូរការងារមកភ្នំពេញ នេះជាឳកាសមួយដែលគាត់ស្វែងរកការសិក្សាបន្ថែម ។ នៅពាក់កណ្តាលឆ្នាំ 2024 **ឆវិន** ចាប់ផ្តើមស្គាល់អ្នកគ្រូ **វាសនា** តាមរយៈបណ្តាញសង្គម គាត់ក៏ចាប់ផ្តើមនូវក្តីស្រម៉ៃជាវិចិត្រកររបស់គាត់ឡើងវិញ ។ បន្ទាប់ពីបានទទួលការបង្ហាត់បង្រៀនកន្លងមក អ្នកគ្រូបាននែនាំពួកគាត់ឲ្យបង្ហាញស្នាដៃជាសាធារណៈ បន្ថែមជាមួយគំនិតបំផុសថ្មី ។ ការងារតាំងបង្ហាញរបស់ពួកគាត់មានចំណងជើងថា “ small work big story”នេះគឺជាស្នាដៃគំនូរដំបូងបំផុតរបស់**ឆវិន** និងមិត្តរួមថ្នាក់ ដែលពួកគាត់លើកយកព្រឹត្តិការណ៍ជំលោះព្រំដែនកន្លងមក កែច្នៃជា ស្នាដៃលើផ្ទាំងគំនូរ ទុកជាការចងចាំនិងរំលឹកដល់ប្រជាជាតិនៅពេលអនាគត។

ជីវប្រវត្តិ **ទូច សុពណ្ណារ៉ា** Touch Sophnara



កើតនៅឆ្នាំ១៩៩៦ ក្នុងខេត្តតាកែវ។ គាត់បានរកឃើញនូវចំណាង់ចំណូលចិត្តរបស់គាត់អំពីសិល្បៈគំនូរតាំងពីនៅវ័យកុមារភាពមកម្លេះ។ កាលនៅតូចគាត់តែងតែអនុវត្តគូរនូវសិល្បៈគំនូរនេះនៅពេលទំនេរពីការសិក្សា។ ក្នុងអំឡុងឆ្នាំ២០០៨ គាត់បានសិក្សាសិល្បៈគំនូរនេះនៅក្នុងអង្គការមួយកន្លែងនៅឯស្រុកកំណើត។ចំណែកឯពេលបច្ចុប្បន្ននេះគាត់កំពុងសិក្សាថ្នាក់គំនូរវិចិត្រកម្មក្រៅម៉ោងជារៀងរាល់ចុងសប្តាហ៍ជាមួយអ្នកគ្រូ **ទិត្យ វាសនា**។ស្នាដៃរបស់ **សុពណ្ណារ៉ា** បង្ហាញពីវិបត្តិសង្គ្រាមនៅតាមព្រំដែនខ្មែរដែលថៃបានឈ្លានពានដោយប្រើប្រាស់នូវអាវុធទំនើបៗមកវាយប្រហារលើទឹកដីខ្មែរនាថ្ងៃ ២៤ ខែកក្កដា ឆ្នាំ ២០២៥។ គាត់បានទាញយកប្រធានបទអំពីបទល្មើសដែលថៃបានប្រព្រឹត្តមកលើកម្ពុជាអំឡុងពេលមានសង្គ្រាមដែលមានដូចជាការទម្លាក់គ្រាប់បែកមកលើប្រាសាទព្រះវិហារ ការទម្លាក់គ្រាប់មកលើផ្ទះសម្បែងរបស់ប្រជាជនខ្មែរនៅតាមព្រំដែន ការប្រើផ្សែងពុលនិងការវាវមីនដោយខុសច្បាប់លើទឹកដីកម្ពុជា ដើម្បីជាភស្តុតាងនិងការចងចាំដល់ប្រជាជនខ្មែរគ្រប់រូប។ សម្រាប់គោលគំនិតនេះផងដែរគឺការផ្តួចផ្តើមដំបូងនិងមានការណែនាំតម្រង់ព្រមទាំងសម្របសម្រួលដោយផ្ទាល់ពីអ្នកគ្រូហើយក៏មានការចូលរួមពីស្នាដៃសិល្បៈដទៃទៀតរបស់មិត្តរួមថ្នាក់របស់គាត់ផងដែរ។ ចំពោះគោលគំនិតសំខាន់នៃពិព័រណ៍ស្នាដៃរបស់ក្រុមពួកគាត់នេះគឺចង់ប្រើនូវគំនិតនិងស្នាដៃសិល្បៈរបស់ពួកគាត់ដើម្បីផ្សារភ្ជាប់និងឆ្លុះបញ្ចាំងពីទិដ្ឋភាពសង្គមខ្មែរបច្ចុប្បន្នដែលបានទទួលរងនូវការឈ្លានពានពីប្រទេសថៃ។ អ្វីដែលសំខាន់ជាងនេះទៅទៀតគឺគាត់មានគោលគំនិតចង់ធ្វើការចូលរួមកត់ត្រាពីរឿងរ៉ាវសង្គ្រាមខ្មែរនិងថៃ នាសតវត្សទី២១ ដោយប្រើស្នាដៃសិល្បៈគំនូររបស់គាត់មករៀបរាប់ដើម្បីបង្កើតបាននូវប្រវត្តិសាស្ត្រថ្មីមួយ និងចង់បញ្ជាក់ទៅកាន់ពិភពលោកថាសង្គ្រាមមិនបាននាំមកនូវភាពរីកចម្រើននោះទេ គឺមានតែការចរចារបញ្ចប់សង្គ្រាមទេទើបអាចនាំមកនូវសេចក្តីសុខសន្តិភាពជូនដល់ប្រជាជាតិលើសកលលោកបាន។

ជិវប្រវត្តិ **រ័ត្ន លីនដា** Roth Lindar



កើតឆ្នាំ 1992 នៅទីរួមខេត្តបាត់ដំបង។**លីនដា**នៅចាំបានថា ចំណូលចិត្តគូររូបដំបូងគឺនៅពេលរៀនបឋមសិក្សាថ្នាក់ទី3។ កាលនោះ មុខវិជ្ជាដែលនាងចូលចិត្តជាងគេគឺម៉ោងគំនូរ ហើយតែងតែបានពិន្ទុលើសគេនិងត្រូវអ្នកគ្រូយកតាំងបង្ហាញលើជញ្ជាំងថ្នាក់។ បើមានគេសួរថាពេលទំនេរចូលចិត្តធ្វើអ្វី នាងនឹងឆ្លើយថាចូលចិត្តគូររូប។ នៅឆ្នាំ 2020 ជំងឺរាតត្បាតកូវីតមកដល់ មានការបិទខ្ទប់ មិនអាចទៅធ្វើការប្រចាំថ្ងៃបាន មិនអាចចេញពីផ្ទះបាន នាងក៏ចាប់ផ្តើមមានពេលគូររូបច្រើនជាងមុន។ ពេលនោះគំនូរមិនត្រឹមតែជួយបំបាត់អផ្សុកប៉ុណ្ណោះទេ ថែមទាំងជួយព្យាបាលអារម្មណ៍ភ័យខ្លាចនិងភាពតានតឹងនៃអារម្មណ៍ក្នុងកំឡុងពេលបិទខ្ទប់ដ៏លំបាកនោះផងដែរ។ **លីនដា**ក៏ចាប់ផ្តើមស្រលាញ់និងចូលចិត្តការគូររូបខ្លាំងជាងមុន រហូដល់ពាក់កណ្តាលឆ្នាំ 2024 នាងបានស្គាល់អ្នកគ្រូ**វាសនា** និងបានចូលរៀនថ្នាក់គំនូរក្រៅម៉ោងជាមួយគាត់។ ពេលនោះ **លីនដា**ចាប់ផ្តើមរៀនពីមូលដ្ឋានគ្រឹះគំនូរឡើងវិញ ហើយអ្នកគ្រូបានជួយណែនាំនិងជំរុញបំផុសគំនិតច្នៃប្រឌិតបន្ថែមទៀតផងដែរ “Small work, big story” នេះគឺជាស្នាដៃគំនូរដំបូងបំផុតរបស់នាងនិងមិត្តរួមថ្នាក់ ដែលពួកគាត់លើកយកហេតុការណ៍ជំលោះព្រំដែនកន្លងមក មកកែច្នៃជាស្នាដៃ លើផ្ទាំងគំនូរ ទុកជាការចងចាំនិងរំលឹកព្រឹត្តិការប្រវត្តិសាស្រ្តនៅពេលអនាគត។

**Roth Linda**, born in Battambang, Cambodia.
Title of my art work: Boycott reminder series
Size: 50cmx50cm (250$)
Media: Acrylic on canvas



Sometimes, we don't realize that the money we spend on an imported product goes beyond just buying that item. Our money may end up helping another country strengthen its economy—or even support actions that harm our own. Spend wisely and support local products. For example, a pizza brand owned by a Thai company is just one of many imported products that Cambodians are now choosing to boycott.



Boycott reminder (250$)



Mind your steps (250$)



The poison mask protection (250$)



Boycott better than weapon war (250$)



Our Soldiers our hero (250$)



**Sophonara TOUCH**

Takeo province

Title : Who Started the War series

Size : 50cmx70cm (300$)

Media: Acrylic on canvas



Justice for Preah Vihear (300$)



Horror scene at the border (300$)



Poison gas weapon of war (300$)



Treasure mount not eggplants hill (300$)



Mine Discovery performance (300$)



Clash bombs and the civilian village (300$)

**Chhavin NAM**

Tile of my painting: no war no arm forces but peace series

Size: 60cm x 80cm (350$)

Media: Acrylic on canvas





Parrot the trouble maker I (350$)



Parrot the trouble maker II (350$)



Observation on the conflict (350$)



Press the play mode (350$)



Eagal is a peace maker (350$)



**Meas Sreyroth**, born in Phnom Penh

Title: My Homeland series

Size: 60cmx60cm (320$)

Media: Acrylic on canvas



Objects of invasion at border dispute (320$)



Disasters after the war (320$)





Tents by the border (320$)

Ceasefire violation (320$)



Used tile and barbed wire (320$)